**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**
**Cambodian Center for Human Rights**

# ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌
# សិទ្ធិទទួលបានមេធាវី

www.cchrcambodia.org

ខែកក្កដា ឆ្នាំ២០២៦

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បានសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញនៅឆ្នាំ២០១៣ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌ និងវាយតម្លៃអំពីការអនុវត្តការជំនុំជម្រះដោយយុត្តិធម៌ ផ្អែកតាមបទដ្ឋានជាតិ និងអន្តរជាតិ។ នៅឆ្នាំ២០២២ ម.ស.ម.ក បានពង្រីកការសង្កេតសវនាការព្រហ្មទណ្ឌរបស់ខ្លួននៅសាលាឧទ្ធរណ៍បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ។ ព្រឹត្តិបត្រព័ត៌មាននេះ បានវិភាគលើរបកគំហើញពីការសង្កេតសវនាការពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤។ ព្រឹត្តិបត្រព័ត៌មាននេះ ផ្តោតលើបញ្ហាប្រឈមចំពោះបុគ្គលទាំងឡាយ ដែលរងការចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌ ជាពិសេស ការទទួលបានមេធាវីការពារលើរឿងក្តីរបស់ពួកគេ។ ទិន្នន័យទាំងអស់ដែលបានប្រមូលមាននៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យសង្កេតសវនាការ ហើយសាធារណជនអាចចូលមើលបាន។

## *សិទ្ធិទទួលបានមេធាវីការពារ*

ផ្នែកមួយដ៏សំខាន់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺការមានឱកាសទទួលបានមេធាវីការពារ។ នីតិវិធីច្បាប់អាចមានភាពស្មុគស្មាញ ហើយប្រសិនបើគ្មានមេធាវីការពារ បុគ្គលដែលរងការចោទប្រកាន់រឿងព្រហ្មទណ្ឌទំនងជាខាតប្រយោជន៍ អាចដោយសារតែខ្វះចំណេះដឹងផ្នែកច្បាប់ និងប្រព័ន្ធតុលាការ និងដោយសារតែគ្មានមេធាវីការពារនៅតុលាការ។ លើសពីនេះទៀត សិទ្ធិទទួលបានមេធាវីរបស់បុគ្គលរងការចោទប្រកាន់រឿងព្រហ្មទណ្ឌ មិនគួរត្រូវបានកម្រិតដោយសារតែមិនមានលទ្ធភាពជួលមេធាវីនោះទេ។ នៅពេលដែលបុគ្គលនោះមិនមានលទ្ធភាពជួលមេធាវីការពារ ច្បាប់តម្រូវថាអាជ្ញាធរពាក់ព័ន្ធគួរផ្តល់មេធាវីការពារដោយគ្មានការបង់សេវា។

**ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា**
**មាត្រា ៣០០**

"...ជនជាប់ចោទត្រូវអមដោយមេធាវីដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីការពារឱ្យខ្លួនបានដែរ ផ្អែកតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"

**កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ឃ)**

"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាន៖....ការការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈមេធាវីដែលខ្លួនជ្រើសរើស និងត្រូវទទួលបានការប្រាប់ឱ្យយល់ដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានមេធាវីការពារ ហើយត្រូវទទួលបានមេធាវីសម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីចំណាយទៅលើការជួលមេធាវី។"

សិទ្ធិទទួលបានមេធាវី គឺជាមូលដ្ឋានគ្រឹះមួយក្នុងការធានានូវភាពស្មើគ្នាចំពោះមុខច្បាប់រវាងតំណាងអយ្យការ និងជនជាប់ចោទ ដែលជាគោលការណ៍ចម្បងនៃការជំនុំជម្រះដោយយុត្តិធម៌។ ការទទួលបានមេធាវីការពារផ្តល់លទ្ធភាពឱ្យជនជាប់ចោទរៀបចំការពារខ្លួនបានល្អបំផុត និងមានប្រសិទ្ធភាពខ្ពស់ តាមរយៈអ្នកជំនាញច្បាប់ដែលអាចពន្យល់គ្រប់ជ្រុងជ្រោយអំពីទិដ្ឋភាពច្បាប់ពាក់ព័ន្ធនឹងការចោទប្រកាន់លើពួកគេ ព្រមទាំង ការពារផលប្រយោជន៍ជនជាប់ចោទនៅតុលាការ។ ការទទួលបានមេធាវីការពារក៏ធានាផងដែរថា គ្រប់ជនជាប់ចោទទទួលបានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងគ្មានការរើសអើង។[1]

## *ក្របខ័ណ្ឌច្បាប់*

ច្បាប់កម្ពុជាបានចែងអំពីសិទ្ធិទទួលបានមេធាវីក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មាត្រា ៣០០ ចែងថា...ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។

មាត្រា ៣០១ នៃក្រមនេះបានចែងថា ជំនួយពីមេធាវីត្រូវតែមានដាច់ខាតក្នុងលក្ខខណ្ឌពីរ៖ ករណីបទឧក្រិដ្ឋ និងជនជាប់ចោទជាអនីតិជន។ ថ្វីបើច្បាប់ជាតិបានធានាយ៉ាងច្បាស់ នូវសិទ្ធិទទួលបានមេធាវីសម្រាប់ជនជាប់ចោទជាអនីតិជន និងជនជាប់ចោទដែលរងការចោទប្រកាន់ពីបទឧក្រិដ្ឋ ប៉ុន្តែច្បាប់នេះ មិនទាន់ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៅឡើយ ចំពោះករណីដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងទៀត ក្រៅពីបទឧក្រិដ្ឋ ឧទាហរណ៍ដូចជា បទមជ្ឈិមជាដើម។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិមិនបានបែងចែកបទល្មើសផ្សេងគ្នាដូច្នេះទេ ហើយផ្ទុយមកវិញ គឺតម្រូវឱ្យសិទ្ធិទទួលបានមេធាវីត្រូវតែអនុវត្តជាលក្ខណៈសាកល និងមិនគិតពី

[1] ម.ស.ម.ក "សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតសវនាការ" (២០១២), ទំព័រ ១៥

file:///C:/Users/carol/Downloads/cchr-ftr-and trial-monitoring-handbook-feb-eng2012-02-13%20(7)

CC BY NC SA

ប្រភេទនៃបទល្មើសឡើយ។[2] ទោះបីយ៉ាងក្តី មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានទទួលស្គាល់ និងគោរពនូវសិទ្ធិទាំងឡាយដែលបានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ នេះបានន័យថា សិទ្ធិទទួលបានមេធាវីត្រូវផ្តល់ឱ្យជនគ្រប់រូបដែលរងការចោទប្រកាន់បទព្រហ្មទណ្ឌ ដូចបានកំណត់ដោយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សមួយចំនួន ធ្លាប់បានលើកឡើងពីការប្រឈមផ្សេងៗរបស់អាជ្ញាធរកម្ពុជា ពាក់ព័ន្ធនឹងភាពលំបាកក្នុងការទទួលបានជំនួយផ្នែកច្បាប់។[3]

## *ការទទួលបានសំណុំរឿងមុនពេលសវនាការ*

យោងតាមមាត្រា៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា ការពិនិត្យមើលសំណុំរឿង មានតែមេធាវី ឬលេខាធិការរបស់មេធាវីទេដែលអាចពិនិត្យមើលសំណុំរឿងមុនពេលសវនាការ និងអាចថតចម្លងសំណុំរឿងទាំងនោះ ផ្ទុយទៅវិញ សម្រាប់ជនជាប់ចោទដែលមិនមានមេធាវីការពារមិនមានសិទ្ធិទទួលបានសំណុំរឿង ដែលជាឯកសារចោទប្រកាន់ប្រឆាំងនឹងខ្លួនបានទេ ដូច្នោះ នេះគឺជាការកម្រិតលទ្ធភាពដល់ជនជាប់ចោទមិនអាចរៀបចំការពារខ្លួនបានគ្រប់គ្រាន់នោះទេ។

## *សិទ្ធិទទួលបានមេធាវីការពារ ជាតួលេខ*

គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានសង្កេតសវនាការនៅសាលាឧទ្ធរណ៍ទាំងបួនពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ ទទួលបានសំណុំរឿងព្រហ្មទណ្ឌចំនួន ១,៨៧៥ ដែលមានចំនួនជនជាប់ចោទ ២,៦៦៤ នាក់ គម្រោងបានវិភាគ និងវាយតម្លៃលើការប្រកាន់ភ្ជាប់របស់ចៅក្រមក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងកម្រិតនៃការគោរពសិទ្ធិទទួលបានមេធាវីរបស់ជនជាប់ចោទនីមួយៗ។

## *សិទ្ធិទទួលបានមេធាវីការពារតាមឆ្នាំនីមួយៗ*

ភាគរយនៃជនជាប់ចោទដែលមានមេធាវីការពារនៅសាលាឧទ្ធរណ៍គោលដៅទាំងបួន៖ នៅឆ្នាំ២០២២ មានចំនួន ៦៦.៧% (៤៨៣ ក្នុងចំណោម ៧២៤នាក់) នៅឆ្នាំ២០២៣ មានចំនួន ៥៨.៧% (៦៥៦ ក្នុងចំណោម ១.១១៨ នាក់) និងនៅឆ្នាំ២០២៤ មានចំនួន ៥៥.៨% (៤៥៩ ក្នុងចំណោម ៨២២ នាក់)។ ជារួម មានចំនួន ៦០% (១៥៩៨ ក្នុងចំណោម ២៦៦៤នាក់) មានមេធាវីការពារ។ ទិន្នន័យនេះបង្ហាញថា បួននាក់ក្នុងចំណោមរៀងរាល់ដប់នាក់ នៅសាលាឧទ្ធរណ៍ទាំងបួនដែលរងការចោទប្រកាន់ពីបទ មជ្ឈិមមិនទទួលបានមេធាវីការពារទេ ដូចនេះវាប៉ះពាល់ដល់លទ្ធភាពក្នុងការការពារខ្លួនបានត្រឹមត្រូវ។

សន្និដ្ឋានជារួម ការទទួលបានមេធាវីការពារមានការថយចុះគួរឱ្យកត់សម្គាល់ជាបន្តបន្ទាប់ពីមួយឆ្នាំទៅឆ្នាំ។ បញ្ហានេះគួរត្រូវបានដោះស្រាយឱ្យបានសមស្រប ដើម្បីធានាថាសិទ្ធិទទួលបានមេធាវីការពារត្រូវបានលើកកម្ពស់ស្របតាមបទដ្ឋានអន្តរជាតិស្តីពីការជំនុំជម្រះដោយយុត្តិធម៌។




លោកអ្នកក៏អាចអានរបាយការណ៍ប្រចាំឆ្នាំ២០២២ ២០២៣ និង២០២៤ ស្តីពី"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ"។

[2] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២, CCPR/C/GC/32, កថាខណ្ឌ ៣៨

[3] AL KHM ៤/២០២៥, https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=30028

## អនុសាសន៍

ម.ស.ម.ក សូមអំពាវនាវដល់ចៅក្រម និងក្រសួងយុត្តិធម៌ គួរជានានូវការអនុវត្តដូចខាងក្រោម៖

- ចៅក្រមគួរលើកកម្ពស់សិទ្ធិទទួលបានមេធាវីជាលក្ខណៈសកល ដោយមិនមានការកម្រិតនៃប្រភេទបទល្មើសដែលជានាដោយច្បាប់អន្តរជាតិ។
- ក្រសួងយុត្តិធម៌គួរពិចារណាស្នើឱ្យវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌដោយអនុញ្ញាតឱ្យជនជាប់ចោទដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ទទួលបានមេធាវីការពារដែលស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា និងបទដ្ឋាន ព្រមទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។
- ក្រសួងយុត្តិធម៌គួរពិចារណាស្នើឱ្យមានវិសោធនកម្មលើមាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទដែលមិនមានមេធាវីការពារទទួលបានសំណុំរឿងរបស់ខ្លួនមុនពេលសវនាការ និងផ្តល់លទ្ធភាពឱ្យជនជាប់ចោទអាចការពារខ្លួនបាន។
- ក្រសួងយុត្តិធម៌គួរខិតខំបន្តទៀតក្នុងការផ្តល់ព័ត៌មានដល់សាធារណជនអំពីសិទ្ធិទទួលបានជំនួយពីមេធាវីដោយឥតបង់ពីរដ្ឋ រួមទាំងការផ្សព្វផ្សាយព័ត៌មាននេះនៅប៉ុស្តិ៍នគរបាលរដ្ឋបាល ពន្ធនាគារ និងអាគាររបស់តុលាការ។
- ក្រសួងយុត្តិធម៌គួរបង្កើតគោលនយោបាយជាតិស្តីពីជំនួយផ្នែកច្បាប់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីជំនួយផ្នែកច្បាប់ និងគួរអនុម័តជាផ្លូវការត្រឹមឆ្នាំ២០២៦។

CC BY NC SA